# បឹងទំពុនៈ អនាគតកាល មើលមិនឃើញ?

***អ្នកភូមិប្រាំនាក់រៀបរាប់អំពីរឿងរ៉ាវរបស់ពួកគេ***

## ការពិត និង តួលេខ
## ខែ កុម្ភៈ ឆ្នាំ ២០១៥ #២៥

គឺជាអត្ថបទបោះពុម្ពផ្សាយស្តីពីបញ្ហាទីក្រុង ដោយសមាគមធាងត្នោត (STT)

សមាគមធាងត្នោត
Sahmakum Teang Tnaut • a Cambodian Urban NGO

បឹងទំពុនគឺជាលំនៅដ្ឋានរបស់ប្រជាពលរដ្ឋប្រមាណ ១.៥០០ គ្រួសារក្នុងសហគមន៍ចំនួន១៣ ផ្សេងៗគ្នានៅជុំវិញបឹង។ តំបន់បឹងទំពុនគ្របដណ្តប់លើផ្ទៃដីប្រហែល ២.៦០០ ហិកតា រាប់បញ្ចូលទាំងផ្ទៃទឹកទំហំ ៥២០ ហិកតា នៅក្នុងខណ្ឌមានជ័យ។ វាដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព្រឹត្តិកម្មសំណល់រាវ និង គ្រប់គ្រងទឹកជំនន់ក្នុងរាជធានីភ្នំពេញ។[១]

នៅពេលទឹកសំណល់ត្រូវបានបញ្ចេញចោល ប្រព័ន្ធបង្ហូរបានបូមទឹកសំណល់ចេញទៅតំបន់វាលភក់ដីសើមនៅខាងត្បូងក្រុង ដូចជាបឹងទំពុនជាដើម។ នៅទីនោះ តម្រងទឹកកខ្វក់ តាមរយៈដំណាំដ៏ក្រាស់បានចាប់យកសារធាតុចិញ្ចឹមពីទឹកសំណល់មុននឹងបញ្ចេញវាទៅក្នុងទន្លេបាសាក់។ បឹងទំពុនក៏ជួយគ្រប់គ្រងទឹកជន់នៅក្នុងរាជធានីផងដែរ។ បឹងនៅជុំវិញរាជធានីភ្នំពេញដើរតួនាទីជាអាងស្តុកទឹកធម្មជាតិដែលរក្សាទុកទឹកភ្លៀងជាបណ្តោះអាសន្នមុននឹងបង្ហូរ ឬបូមទៅកាន់កន្លែងផ្សេងៗ។[២]

ក្នុងឆ្នាំ ២០០៩ រាជរដ្ឋាភិបាលបានផ្តល់គោលការណ៍អនុញ្ញាតឲ្យក្រុមហ៊ុនឯកជនធ្វើការអភិវឌ្ឍន៍បឹងទំពុន។ តាំងពីពេលនោះមក ក្រុមហ៊ុនអភិវឌ្ឍន៍បាននឹងកំពុងចាក់ខ្សាច់បំពេញបឹង។ ដូចបានរំពឹងទុក វាបាននាំមកនូវបញ្ហាគួរឲ្យព្រួយបារម្ភជាច្រើនទាក់ទងនឹងផ្នែកបរិស្ថាន និងអនាម័យ។ ទឹកលិចនៅក្នុងរាជធានីមានកម្រិតខ្លាំងឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ ហើយប្រជាពលរដ្ឋនៅក្នុងសហគមន៍ជុំវិញបានទទួលរងគ្រោះពីទឹកសម្អុយ និងការគំរាមកំហែងពីការបណ្តេញចេញ។



សហគមន៍ដើមស្វាយនៅក្នុងភូមិ ៧ ផ្សារដើមថ្កូវ



ដំណាំត្រកួន និង កញ្ឆែត នៅព្រែកតាគង ១



លំនៅដ្ឋាននៅក្នុងភូមិព្រែកតាគង



ការសាងសង់នៅក្បែរសាលាអន្តរជាតិភ្នំពេញ (ISPP)

## ករណី #១: លោក គុណ សំណាង



លោក គុណ សំណាង នៅខាងក្រៅផ្ទះរបស់គាត់ នៅព្រែកតាគង

ខ្ញុំមានអាយុសែសិបឆ្នាំ និងនៅលីវ។ ខ្ញុំមានស្រុកកំណើតនៅខេត្តតាកែវ ហើយការសិក្សារបស់ខ្ញុំបានត្រឹមថ្នាក់ទី៥។ ខ្ញុំរស់នៅទីនេះអស់រយៈពេលជាង១៥ ឆ្នាំមកហើយ និងមានសមាជិកគ្រួសារ ០៦ នាក់។ ខ្ញុំបានមករស់នៅក្នុងរាជធានីភ្នំពេញជាដំបូងនៅក្នុងឆ្នាំ ១៩៨១ ហើយពេលនោះគ្រួសាររបស់ខ្ញុំបានតាំងលំនៅក្បែរនឹងផ្ទះរបស់ពួកយើងបច្ចុប្បន្ននេះ។ ពីមុនខ្ញុំបានធ្វើការងារនៅឡឥដ្ឋរបស់រដ្ឋ។ បន្ទាប់ពីឡឥដ្ឋឈប់ដំណើរការ គ្រួសាររបស់ខ្ញុំ និងកម្មករឡឥដ្ឋផ្សេងទៀតបានផ្លាស់មករស់នៅទីនេះក្នុងឆ្នាំ១៩៩៨ ហើយកាលនោះមានប្រហែល ២០ គ្រួសារ។

គ្រួសាររបស់ខ្ញុំបានចាប់ដីមួយកន្លែងទំហំ ១៥ម x ២២ម។ បន្ទាប់ពីពួកយើងបានសាងសង់ផ្ទះរបស់យើងហើយ អាជ្ញាធរមូលដ្ឋានមិនផ្តល់លិខិតបញ្ជាក់កម្មសិទ្ធិជូនពួកយើងទេ។ ពួកគេបានប្រកាសថាដីនេះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយគ្មានជនណាម្នាក់អាចកាន់កាប់ ឬយកធ្វើជាកម្មសិទ្ធិរបស់ខ្លួនបានទេ។ ពួកយើងមិនបានយល់ព្រមចំពោះសេចក្តីសម្រេចរបស់អាជ្ញាធរទេពីព្រោះមានពលរដ្ឋ និង ពាណិជ្ជករបានកាន់កាប់ដីមួយចំនួនជាលក្ខណៈឯកជនរួចហើយ។ ដូច្នេះសហគមន៍របស់ខ្ញុំបានដាក់ពាក្យបណ្តឹងទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដនស)។ ទីបំផុតអាជ្ញាធរ បានសម្រាលការគំរាមកំហែងរបស់ពួកគេមួយកម្រិត។ ក្រោយមកទៀតគ្រួសារផ្សេងទៀតបានរើមករស់នៅទីនេះជាបន្តបន្ទាប់ផងដែរ។

ខ្ញុំបានចាប់ផ្តើមដាំបន្លែក្នុងទឹក (ត្រកួន កញ្ឆែត) នៅតំបន់បឹងទំពុនក្នុងឆ្នាំ ២០០៧ តាមរយៈការជួលដីលិចទឹកដែលមានទំហំ ០,៥ ហិកតា។ ខ្ញុំត្រូវចំណាយ ២.០០០.០០០ រៀល (ប្រហែល ៥០០ ដុល្លារអាមេរិក) ក្នុងមួយឆ្នាំដើម្បីជួលដីដាំដុះនេះ។ ខ្ញុំអាចប្រមូលបន្លែរបស់ខ្ញុំចំនួនពីរ ទៅបីដងក្នុងមួយខែ ដោយមានប្រាក់ចំណូល ៣០០.០០០ ទៅ ៤០០.០០០ រៀល (ប្រហែល ៧៥ ទៅ ១០០ ដុល្លារអាមេរិក) ក្នុងមួយខែៗ។ នៅក្នុងឆ្នាំ ២០១១ ការងារអភិវឌ្ឍន៍បានចាប់ផ្តើម ដោយមានការចាក់ខ្សាច់បំពេញ

តំបន់អភិវឌ្ឍន៍។ ខ្ញុំត្រូវចាកចេញពីកន្លែងដាំដុះរបស់ខ្ញុំ ដែលត្រូវចាក់បំពេញដោយខ្សាច់។ ខ្ញុំបានផ្លាស់ទីកន្លែងជាង ៥កន្លែងដើម្បីព្យាយាមក្នុងការដាំបន្លែឲ្យបានកាន់តែច្រើន ប៉ុន្តែកន្លែងទាំងនោះ ក៏ត្រូវបន្តចាក់បំពេញដោយខ្សាច់ទៀត។ ជាលទ្ធផល ខ្ញុំបានបោះបង់មុខរបរនោះនៅពាក់កណ្តាលឆ្នាំ ២០១៣។ ពេលនេះ ខ្ញុំធ្វើជាជាងសំណង់ ប៉ុន្តែខ្ញុំអាចរកប្រាក់បានត្រឹមតែពី ៦០.០០០ រៀល ទៅ ៨០.០០០ រៀល (ប្រហែល ១៥ ទៅ ២០ ដុល្លារអាមេរិក) ប៉ុណ្ណោះក្នុងមួយសប្តាហ៍។



លោកគុណសំណាងនៅលើខ្សាច់ជុំវិញលំនៅដ្ឋានរបស់គាត់នៅព្រែកតាគង

ក្រុមហ៊ុនមិនដែលជូនដំណឹងដល់សហគមន៍អំពីការងារអភិវឌ្ឍន៍ទេ។ ក្នុងឆ្នាំ ២០១៣ អាជ្ញាធរមូលដ្ឋានបានមកវាស់វែងលំនៅដ្ឋាន របស់យើងខ្ញុំដោយមិនជូនដំណឹងដល់ម្ចាស់ ដែលធ្វើឲ្យយើងខ្ញុំមានការព្រួយបារម្ភអំពីលំនៅដ្ឋានរបស់យើងខ្ញុំ។ ខ្ញុំពិតជាមានការភ័យខ្លាចការបណ្តេញចេញណាស់ពីព្រោះ ខ្ញុំពុំមានប័ណ្ណកម្មសិទ្ធិដីស្របច្បាប់ទេ។ អាជ្ញាធរមូលដ្ឋានមិនដែលគាំទ្រដល់ការតាំងលំនៅដ្ឋានរបស់យើងខ្ញុំទេ និងបានបដិសេធន៍មិនបញ្ជាក់លើលំនៅដ្ឋាននេះទៀត។ ខ្ញុំបារម្ភថាអាជ្ញាធរនឹងបន្តធ្វើបាបយើងខ្ញុំ និងបណ្តេញយើងខ្ញុំឲ្យធ្វើការតាំងលំនៅថ្មី។ កាលពីមុនខ្ញុំពិតជារីករាយជាមួយនឹងជីវភាពរស់នៅយ៉ាងសាមញ្ញរបស់ខ្ញុំ រួមជាមួយបឹងធម្មជាតិ និងបរិស្ថានបៃតងខ្លាំងណាស់។ ខ្ញុំមានការខកចិត្តយ៉ាងខ្លាំងដែលបាត់បង់បឹង។

# ករណី #២: អ្នកស្រី យុត សារ៉េន

ខ្ញុំមានអាយុសែសិបបីឆ្នាំ និងមានសមាជិកគ្រួសារ ១២ នាក់ (៧នាក់មកពីគ្រួសាររបស់ខ្ញុំផ្ទាល់ និង ៥ នាក់ទៀតជាចៅៗ)។ ខ្ញុំមានស្រុកកំណើតនៅស្រុកអង្គរបុរី ខេត្តតាកែវ។ ខ្ញុំបានឈប់រៀននៅថ្នាក់ទី ២ ហើយឪពុកម្តាយរបស់ខ្ញុំបានស្លាប់ក្នុងរបបប៉ុលពត។ ខ្ញុំមានផែនការធ្វើស្រែនៅខេត្ត ប៉ុន្តែមិនបានជោគជ័យ ដូច្នេះ ខ្ញុំបានសម្រេចចិត្តមករាជធានីភ្នំពេញដើម្បីស្វែងរកការងារធ្វើ។



អ្នកស្រី យុត សារ៉េន នៅផ្ទះរបស់គាត់នៅក្នុងភូមិត្នោតជ្រុំ

នៅពេលខ្ញុំផ្លាស់មករស់នៅ រាជធានីភ្នំពេញដំបូង ខ្ញុំបានស្នាក់នៅជាមួយនឹងបងប្អូនប្រុសរបស់ខ្ញុំ ដែលជាគ្រូបង្រៀននៅក្បែរផ្សារប៉េសេនៅក្នុងខណ្ឌមានជ័យ ហើយខ្ញុំបានរស់នៅទីនោះអស់រយៈពេល ៧ឆ្នាំ។ គ្រួសាររបស់ខ្ញុំបានសន្សំប្រាក់បានខ្លះ ហើយពួកយើងបានសម្រេចចិត្តទិញដីមួយកន្លែងនៅតំបន់បឹងទំពុន។ វាមានតម្លៃសមរម្យ ហើយលក្ខខណ្ឌរស់នៅគឺអាចទទួលយកបាននៅពេលនោះ។ លំនៅដ្ឋានបច្ចុប្បន្នរបស់ខ្ញុំមានការបញ្ជាក់ពីភូមិ ឃុំ/សង្កាត់។

នៅក្នុងភូមិត្នោតជ្រុំនេះ ខ្ញុំគឺជាកសិករ (ដែលដាំបន្លែទឹកដូចជា ត្រកួន និងកញ្ឆែត) ហើយខ្ញុំបានចាប់ផ្តើមការដាំដុះនេះ នៅដើមឆ្នាំ ២០០៧។ ខ្ញុំអាចរកប្រាក់ចំណូលបានពី ៤០.០០០ រៀល–៥០.០០០ រៀល (ប្រហែល ១០–១២,៥០ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ ទោះបីជាយ៉ាងណា ខ្ញុំត្រូវចំណាយប្រហែល ៣០.០០០ រៀល ទៅ ៤០.០០០ រៀល (ប្រហែល ៧,៥០ ទៅ ១០

ដុល្លារអាមេរិក)សម្រាប់ការចាយវាយប្រចាំថ្ងៃក្នុងគ្រួសារ និងសម្រាប់ការរៀនសូត្ររបស់កូនៗខ្ញុំ។ ពេលខ្លះខ្ញុំចង់បោះបង់ការងារនេះ ពីព្រោះវាជាការងារកខ្វក់ ក្លិនមិនល្អ និងប៉ះពាល់សុខភាព។ ដោយសារខ្ញុំមានកម្រិតវប្បធម៌ទាប ខ្ញុំមិនអាចស្វែងរកការងារល្អជាងនេះទេ។

ថ្មីៗនេះ នៅពេលក្រុមហ៊ុនអភិវឌ្ឍន៍មកដល់ អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្តូរ។ វាមានផលប៉ះពាល់មិនល្អយ៉ាងខ្លាំងមកលើមុខរបររបស់ខ្ញុំ។ ខ្ញុំត្រូវផ្លាស់ទីទៅជួលកន្លែងដាំដុះផ្សេងទៀត ដែលឆ្ងាយពីកន្លែងចាស់របស់ខ្ញុំ ដោយសារទីតាំងនេះត្រូវបានចាក់បំពេញដោយខ្សាច់។ ជាលទ្ធផល តម្លៃឈ្នួលដីដាំដុះបានកើនឡើងយ៉ាងខ្លាំង ពី ៥០០ ទៅ ១០០០ ដុល្លារអាមេរិក ក្នុងមួយហិកតាក្នុងមួយឆ្នាំដោយសារកង្វះដីដាំដុះ។ ខ្ញុំក៏ត្រូវចំណាយបន្ថែមលើការធ្វើដំណើរទៅកន្លែងដាំដុះថ្មីរបស់ខ្ញុំ។ ផលបន្លែទឹកដែលបានដាំ (ត្រកួន កញ្ឆែត) បានធ្លាក់ចុះបន្តិចម្តងៗ ដោយសារកន្លែងដាំថ្មីមានទឹករាក់មិនអំណោយផល និងពេញទៅដោយទឹកកខ្វក់។ ហើយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ បានបណ្តាលឲ្យមានទឹកលិចលំនៅដ្ឋានរបស់ខ្ញុំ។

ក្នុងឆ្នាំ ២០១១ ក្រុមហ៊ុនមិនបានសាងសង់ជញ្ជាំងជុំវិញតំបន់អភិវឌ្ឍន៍ទេ។ ជាលទ្ធផល មានធូលីជាច្រើនបានហុយមកលើលំនៅដ្ឋានរបស់យើងខ្ញុំ។ នៅពេលនោះមានគ្រួសារខ្លះ (រាប់បញ្ចូលទាំងគ្រួសាររបស់ខ្ញុំផង) បាននិយាយថា "យើងនឹងលក់លំនៅដ្ឋានរបស់យើងដល់អ្នកណាក៏បានទោះក្នុងតម្លៃណាក៏ដោយ ពី-ព្រោះយើងកំពុងតស៊ូនឹងស្ថានភាពដ៏អាក្រក់នេះ"។

ខ្ញុំពិតជាខ្លាចគេបណ្តេញចេញដោយបង្ខំ ខ្លាំងណាស់។ ខ្ញុំមិនកុំចង់រើចេញ ឬតាំងលំនៅថ្មីទេពីព្រោះខ្ញុំអាចទទួលបានសេវាសាធារណៈយ៉ាងស្រួលនៅទីនេះ នៅក្នុងតំបន់ក្រុងនេះ។ យើងគ្រប់គ្នាដឹងអំពីករណីអ្នករស់នៅបុរីកីឡា និងបឹងកក់ នៅពេលដែលអ្នករស់នៅទីនោះ ត្រូវបានបង្ខំឲ្យរើចេញពីលំនៅដ្ឋានរបស់ពួកគេដោយពុំមានផ្តល់សំណងសមស្រប។ អ្នកមានឈ្នះជានិច្ច និងទទួលបាននូវផលប្រយោជន៍ រីឯអ្នកក្រគឺងាយរងគ្រោះ។

## ករណី #៣: សោម ស្រីលីន*

ខ្ញុំអាយុសាមសិបមួយឆ្នាំ ព្រមទាំងបានរៀបការហើយ និងមានកូនមួយនាក់។ ខ្ញុំបានឈប់រៀននៅថ្នាក់ទី៣ បន្ទាប់ពីគណបក្សប្រជាជនកម្ពុជា (CPP) បានធ្វើរដ្ឋប្រហារនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ១៩៩៧។ យើងខ្ញុំក្រណាស់នៅពេលនោះ។

បច្ចុប្បន្ន ខ្ញុំធ្វើការងារជាអ្នកដាំបន្លែ (ត្រកួន និងកញ្ឆែត) ហើយវាគឺជាប្រភពចម្បងនៃប្រាក់ចំណូលរបស់គ្រួសារខ្ញុំ។ ដោយមានល័ក្ខខ័ណ្ឌអំណោយផល ខ្ញុំអាចដាំប្រភេទបន្លែទាំងនេះទាំងក្នុងរដូវវស្សា និងរដូវ ប្រាំង។ លំនៅដ្ឋានបច្ចុប្បន្នរបស់យើងខ្ញុំនៅភូមិព្រែកបាគង គឺជាស្រុកកំណើតរបស់ខ្ញុំ ហើយខ្ញុំរស់នៅក្នុងភូមិនេះរយៈពេល ៣១ ឆ្នាំមកហើយមកទល់នឹងពេលនេះ។ បឹងទំពុនផ្តល់មុខរបរដល់អ្នករស់នៅទីនេះភាគច្រើន។ នៅពេលខ្ញុំនៅក្មេង គ្រួសារខ្លះបានធ្វើស្រែ ដាំដំណាំចម្រុះដូចជា ត្រកួន កញ្ឆែត ឈូក ព្រលិត និងនេសាទ។

ខ្ញុំសម្រេចចិត្តប្រើប្រាស់ពេលវេលាទាំងអស់របស់ខ្ញុំទៅលើមុខរបរនេះ ពីព្រោះវាមានតម្រូវការទីផ្សាររៀងរាល់ថ្ងៃ។ ដោយសារខ្ញុំមានកម្រិតវប្បធម៌ទាប និងចំណេះដឹងផ្នែកអាជីវកម្មមានកម្រិត ខ្ញុំមិនអាចរកការងារបានល្អជាងនេះទេ។ ខ្ញុំអាចរកប្រាក់ចំណូលបានចន្លោះពី ៤០០.០០០ ទៅ ៥០០.០០០ រៀល (ប្រហែល ១០០ ទៅ ១២៥ ដុល្លារអាមេរិក) ក្នុងមួយខែ ពីការលក់ កញ្ឆែត និងរកប្រាក់ចំណូលបានពី ២០០.០០០ ទៅ ៣០០.០០០ រៀល (ប្រហែល ៥០ ទៅ ៧៥ ដុល្លារអាមេរិក) ក្នុងមួយខែ ពីការលក់ត្រកួន។

ខ្ញុំធ្លាប់រស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំ នៅលើដីដែលមានទំហំ ១៥ x ១៨ ម៉ែត្រ ដែលមានការបញ្ជាក់ពីសង្កាត់។ ខ្ញុំបានរៀបការក្នុងឆ្នាំ ២០០៧ ហើយប្តីរបស់ខ្ញុំ និង ខ្ញុំបានសាងសង់ផ្ទះផ្ទាល់ខ្លួនរបស់ពួកយើងក្នុងឆ្នាំ ២០១៣។ ពួកយើងបានទិញដីមួយកន្លែងពីអ្នកភូមិម្នាក់

ទៀតដែលមានទំហំ ៥ x ១២ ម៉ែត្រ។ ប្រធានភូមិក៏បានបញ្ជាក់លើដីថ្មីរបស់ពួកយើងផងដែរ។

ពួកយើងបានឮពាក្យចចាមអារាម ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍នៅក្នុងសហគមន៍ របស់យើងក្នុងឆ្នាំ ២០១៣ នៅពេលឃុំ/សង្កាត់បានមក និងបានប្រាប់ពួកយើងដោយមិនច្បាស់លាស់ថា "សូមកុំបារម្ភអំពីគម្រោងអភិវឌ្ឍន៍នៅជុំវិញលំនៅឋានរបស់អ្នក។ វានឹងមិនប៉ះ-ពាល់ដល់គ្រួសាររបស់អ្នកទេ។ ប្រសិនបើមានផលប៉ះ-ពាល់ណាមួយនោះ វានឹងមានការផ្ដល់សំណងក្នុងតម្លៃមួយសមរម្យ"។ នៅពេលខ្ញុំបានឮវា ខ្ញុំមានការភ័យខ្លាចត្រូវរងនូវការបណ្ដេញចេញដោយបង្ខំយ៉ាងខ្លាំង ពីព្រោះផ្ទះរបស់ខ្ញុំ និងអ្នកផ្សេងទៀតមិនមានប្លង់កម្មសិទ្ធិចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទេ។ យើងខ្ញុំធ្លាប់បានដឹងរួចមកហើយអំពីការបណ្ដេញចេញដោយបង្ខំដោយអាជ្ញាធរតាមរយៈកងកម្លាំង និងអំពីហិង្សានៅក្នុងសហគមន៍ផ្សេងទៀត (ឧ. បឹងកក់ និងបុរីកីឡា)។

មានផលប៉ះពាល់ធ្ងន់ធ្ងរជាច្រើន ដែលគម្រោងមានមកលើសហគមន៍របស់យើងខ្ញុំ ដូចជាការលំបាកក្នុងការធ្វើដំណើរ និងការលិចទឹកជាប្រចាំ។ លើសពីនេះទៅទៀត សហគមន៍ត្រូវរងនូវធូលីដីហុយជានិច្ច និងពេលខ្លះគ្រាន់តែទទួលទានអាហារក៏លំបាកដែរ។ ខ្ញុំមិនសង្ឃឹមថា គម្រោងនេះនឹងផ្ដល់នូវអត្ថប្រយោជន៍ដល់សហគមន៍ទាំងមូលទេ។ ខ្ញុំជឿថាវានឹងមានផលប៉ះពាល់អវិជ្ជមានមកលើស្ថានភាពសេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងខ្ញុំ។

ខ្ញុំមានការបារម្ភ និងខ្លាចថានៅពេលគម្រោងនេះចប់ ពួកគេនឹងបណ្ដេញអ្នកក្រដែលរស់នៅក្នុងតំបន់នេះចេញ។ ខ្ញុំចង់បានដំណោះស្រាយលើកកម្ពស់នៅនឹងកន្លែង ជាជាងការរើលំនៅដ្ឋានទៅតាំងនៅតំបន់ថ្មី។ ប៉ុន្តែប្រសិនបើក្រុមហ៊ុនស្នើឲ្យយើងខ្ញុំរើលំនៅដ្ឋាន នោះយើងខ្ញុំនឹងទាមទារនូវដំណោះស្រាយ ឬសំណងសមរម្យមួយ។

** ឈ្មោះត្រូវបានប្ដូរដើម្បីរក្សានូវអនាមិកភាព*

# ករណី #៤: អ្នកស្រី ថូ សារុំ




អ្នកស្រី ថូ សារុំ ឈរក្បែរលំនៅដ្ឋានរបស់គាត់នៅក្នុងសហគមន៍ដើមស្វាយ

ខ្ញុំមានអាយុសែសិបឆ្នាំ ជាស្ត្រីមេម៉ាយមានកូន ៣នាក់។ ខ្ញុំរស់នៅដំបូងក្នុងតំបន់បឹងទំពុននេះក្នុងឆ្នាំ ១៩៩០ ដោយមានការទទួលស្គាល់ពីប្រធានភូមិ និងថ្នាក់សង្កាត់។ នៅពេលខ្ញុំបានរស់ នៅក្នុងសហគមន៍ដើមស្វាយ ពេលខ្លះគឺមានទឹកលិច ប៉ុន្តែទឹកមានសភាពស្អាត ហើយបរិស្ថានមិនមានការបំពុលទេនៅពេលនោះ។ នៅទីនេះក៏ដូចគ្នា ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិ-ភាព ខ្ញុំមិនដែលត្រូវបាននរណាម្នាក់ប្លន់នោះទេនៅក្នុងសហគមន៍របស់ខ្ញុំ។

ខ្ញុំធ្លាប់ធ្វើជាអ្នកលក់ដូរ (លក់សម្លៀកបំពាក់) នៅផ្សារហេងលី ប៉ុន្តែខ្ញុំបោះបង់មុខរបរនោះបន្ទាប់ពីរកស៊ីបាន ៣ឆ្នាំពីព្រោះទីនោះខ្ញុំទទួលបានប្រាក់ចំណូលតិចពេកហើយផ្សារនៅឆ្ងាយពីផ្ទះ។ ឥឡូវនេះខ្ញុំធ្វើការងារជាអ្នកដាំបន្លែទឹក។ល។ មុខរបរនេះខ្ញុំអាចរកប្រាក់ចំណូលបានប្រហែល ៦០.០០០ រៀល ទៅ ៨០.០០០ រៀល (១៥–២០ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយខ្ញុំត្រូវចំណាយប្រហែល ៣០.០០០ រៀល (៧,៥ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃសម្រាប់ការរៀនសូត្រ និងចំណីអាហារកូនៗរបស់ខ្ញុំ។

នៅចុងឆ្នាំ ២០១៤ មុនព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុកបន្តិច សង្កាត់ និង ក្រុមហ៊ុនបានអញ្ជើញគ្រួសាររងការប៉ះពាល់ចំនួន ៤២ គ្រួសារ (រាប់បញ្ចូលទាំងគ្រួសាររបស់ខ្ញុំ) នៅក្នុង

តំបន់នេះទៅចូលរួមប្រជុំ។ ពួកគេបាននិយាយថា "លំនៅដ្ឋានរបស់អ្នកនឹងត្រូវប៉ះពាល់ដោយការសាងសង់មហាវិថីសម្ដេចតេជោ ហើយគ្រួសារទាំងនោះនឹងត្រូវបានសងសំណងជូន"។ ប៉ុន្តែពួកគេមិនទាន់បានប្រាប់យើងខ្ញុំថា តើពួកគេមានផែនការសងដល់យើងខ្ញុំប៉ុន្មាននោះទេ។ ពាក្យចចាមអារាមដែលខ្ញុំបានលឺពីគ្រួសារផ្សេងទៀតគឺថា ក្រុមហ៊ុនបានស្នើផ្ដល់ជូន ៣៥០ ដុល្លារអាមេរិកក្នុងដីមួយម៉ែត្រការ៉េ (ម$^{២}$) ប៉ុន្តែពុំមាននរណាម្នាក់រីករាយនឹងតម្លៃនេះទេ។ ផ្ទុយទៅវិញយើងខ្ញុំស្នើសុំយ៉ាងតិចបំផុត ១.០០០ ដុល្លារអាមេរិកក្នុងមួយម៉ែត្រការ៉េ (ម$^{២}$)។ វាក៏មានពាក្យចចាមអារាមផងដែរថា ក្រុមហ៊ុនបានគំរាមដល់គ្រួសារដែលរងការប៉ះពាល់ថា "អ្នកគួរទទួលយកតម្លៃដែលបានស្នើឡើង បើមិនដូច្នេះទេអ្នកនឹងមិនទទួលបានអ្វីទាំងអស់"។

ខ្ញុំមិនប្រាកដទេថា តើគម្រោងអភិវឌ្ឍន៍នឹងផ្ដល់អត្ថប្រយោជន៍ ដល់ប្រជាពលរដ្ឋក្រីក្រដូចជាខ្ញុំដែរឬទេ សូម្បីតែតំបន់នេះ វាក៏នឹងក្លាយជាទីក្រុងទំនើបដែរដែលមានហេដ្ឋារចនាសម្ព័ន្ធល្អៗ។ ប្រសិនបើពួកគេវាយកម្ទេចផ្ទះរបស់ខ្ញុំ នោះវានឹងមានតែទុក្ខសោកប៉ុណ្ណោះ។ ការអភិវឌ្ឍន៍ជានិច្ចកាលល្អសម្រាប់អ្នកមាន ប៉ុន្តែជានិច្ចកាលប៉ះពាល់ដល់អ្នកក្រ។

បឹងទំពុន គឺជាបឹងធម្មជាតិដ៏ស្អាតដែលមនុស្សជានិច្ចកាលតែងរីករាយនឹងទស្សនីយភាពរបស់វា។ ខ្ញុំមិនសប្បាយចិត្តទេដែលបាត់បង់បឹងនេះ ប៉ុន្តែរាជរដ្ឋាភិបាលចង់ធ្វើការអភិវឌ្ឍន៍បន្ថែមទៀត។

ខ្ញុំមានអាយុសែសិបប្រាំពីរឆ្នាំ ជាស្ត្រីមេម៉ាយមានកូនម្នាក់។ ខ្ញុំរៀនមិនបានចប់បឋមសិក្សាផងពីព្រោះគ្រួសាររបស់ខ្ញុំក្រីក្រខ្លាំងណាស់នៅពេលនោះ។ បច្ចុប្បន្ន ខ្ញុំរស់នៅជាមួយនឹងបងប្អូនស្រីរបស់ខ្ញុំនៅក្នុងភូមិទួលរកា ៤ សង្កាត់ចាក់អង្រែក្រោម។

# ករណី #៥: អ្នកស្រី អោម សុភាព



អ្នកស្រី អោម សុភាព រស់នៅក្នុងភូមិទួលរកា ៤

បន្ទាប់ពីរបបប៉ុលពតដួលរលំ មនុស្សជាច្រើននាក់បានមកតាំងលំនៅក្នុងសហគមន៍នេះបន្តិចម្ដងៗ។ ខ្ញុំបានទិញដីមួយកន្លែងជាប់នឹងវាលភក់ល្បប់ ក្នុងឆ្នាំ ១៩៩០ និងបានបញ្ចប់ការសាងសង់ផ្ទះរបស់ខ្ញុំក្នុងឆ្នាំ ១៩៩៧។ ដីនេះត្រូវបានបញ្ជាក់ដោយប្រធានក្រុម និងប្រធានភូមិនៅពេលនោះ។

ខ្ញុំធ្លាប់ធ្វើការនៅហាងថែរក្សាសម្ផស្ស។ ខ្ញុំអាចរកចំណូលបានប្រហែល ៤០.០០០ ទៅ ៥០.០០០ រៀល (ប្រហែល ១០-១២,៥០ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ ដើម្បីជាប្រភពចំណូលបន្ថែម យើងខ្ញុំបានដាំឈូកនៅក្នុងវាលភក់ល្បប់នៅបឹងទំពុន ក្បែរផ្ទះរបស់ខ្ញុំ ដែលខ្ញុំបានទិញពីអ្នកជិតខាង។ ខ្ញុំបានប្រមូលផលជាផ្កា និងគ្រាប់ឈូកហើយលក់វានៅទីផ្សារដែលជាធម្មតា ទទួលបានប្រាក់ចំណូលពី ៦០.០០០ ទៅ ៨០.០០០ រៀល (ប្រហែល ១៥-២០ ដុល្លារអាមេរិក) ក្នុងមួយសប្ដាហ៍។

ក្រោយមក ខ្ញុំបានសម្រេចបោះបង់ការងារពីរនេះ ហើយឥឡូវនេះខ្ញុំបើកអាជីវកម្មខ្នាតតូចលក់អាហារតាមផ្លូវ (បង្អែម ភេសជ្ជៈ និងផ្លែឈើ) សម្រាប់សិស្សបឋមសិក្សា ដែលអាចរកប្រាក់បានបន្តិចបន្តួច។ ខ្ញុំអាចរកប្រាក់បានចន្លោះពី ១២០ ទៅ ១៣០ ដុល្លារអាមេរិកក្នុងមួយខែពីការជួលបន្ទប់ឲ្យកម្មកររោងចក្រ នៅក្នុងតំបន់នេះ។ ការចាក់ខ្សាច់បំពេញនៅក្នុងតំបន់អភិវឌ្ឍន៍មិនត្រឹមតែបានបង្ខំឲ្យខ្ញុំឈប់ការជួលបន្ទប់ប៉ុណ្ណោះទេ វា

ថែមទាំងបានប៉ះពាល់ដល់មនុស្សជាច្រើននាក់ផ្សេងដែរ ដែលផ្អែកលើតំបន់នេះសម្រាប់ការរកប្រាក់ចំណូល។



ផ្ទះរបស់ អ្នកស្រី អោម សុភាព នៅភូមិទួលរកា ៤

ប្រធានភូមិ បានប្រាប់យើងខ្ញុំយ៉ាងច្បាស់លាស់ថា “ដីនៅក្នុងតំបន់នេះនឹងត្រូវប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ផ្លូវសម្តេច ហ៊ុន នាង”។ គាត់ក៏បានស្នើឡើងថា គ្រួសារទាំងអស់ដែលរស់នៅក្បែរទីតាំងគួរចាកចេញពីលំនៅដ្ឋានរបស់ខ្លួន និង ដួលកន្លែងណាមួយផ្សេងទៀតសម្រាប់រយៈពេល ៧ ទៅ ៨ ខែ ដើម្បីឲ្យពួកគេអាចអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ ហើយអាជ្ញាធរបានអះអាងថា ពួកគេនឹងទទួលខុសត្រូវលើថ្លៃឈ្នួលដែលបានកើតមាន សម្រាប់គ្រួសាររងការប៉ះពាល់ទាំងនោះក្នុងអំឡុងពេលនេះ។ លើសពីនេះទៅទៀត ពួកគេបានសន្យាផ្តល់សំណងដល់គ្រួសារ រងការប៉ះពាល់ទាំងអស់ជាដី និងផ្ទះជាក់ស្តែងដែលស្មើនឹងដី និងផ្ទះរបស់យើងខ្ញុំនាពេលបច្ចុប្បន្ន ប្រសិនបើយើងខ្ញុំយល់ព្រមរើចេញ។ ទោះបីជាយ៉ាងណាពួកគេបានបង្ហាញដល់យើងខ្ញុំនូវរូបភាពកន្លែង តាំងទីលំនៅថ្មីដែលពួកគេបានស្នើឲ្យយើងខ្ញុំរើទៅ ហើយវាជាដីគ្មានដីជាតិ គ្មានលំនៅដ្ឋាន និងលិចទៅដោយទឹក។ យើងខ្ញុំមិនយល់ទាំងស្រុងអំពីដំណើរការចរចារវាងគ្រួសាររងការប៉ះពាល់ នៅក្នុងតំបន់នេះ និងអាជ្ញាធរ។ គ្រួសាររងការប៉ះពាល់ទាំងអស់មានការជំទាស់យ៉ាងខ្លាំង ទៅនឹងការស្នើឡើងនោះ ហើយបានប្រកាសថាពួកគេកំពុងរស់នៅស្របច្បាប់ លើដីរបស់ពួកគេ។ ពួកគេបាននិងកំពុងរស់នៅក្នុងតំបន់នេះអស់ជាច្រើនឆ្នាំមកហើយគឺចាប់តាំងពីរបប ប៉ុល ពត ដួលរលំមកម្ល៉េះ។ ពួកគេភាគច្រើនបានទាមទារប្រាក់សំណងសមស្រប។ មនុស្សជាច្រើននាក់ (រាប់បញ្ចូលទាំងខ្លួនខ្ញុំ) កំពុងរស់នៅក្នុងភាពភ័យខ្លាចការបណ្តេញចេញដោយបង្ខំ។ ខ្ញុំមិនរីករាយជាមួយនឹងគម្រោងសាងសង់បច្ចុប្បន្ន ឬផ្លូវសម្តេច ហ៊ុន នាង នោះទេ។ វាបាននាំឲ្យមានការបាត់បង់បឹងរបស់យើង និងបានរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឱកាស ប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។

***អត្ថប្រយោជន៍នៃបឹងទំពុន:***

- *ផ្តល់ឱកាសការងាររកប្រាក់ចំណូល ប្រជាពលរដ្ឋអាចនេសាទ និងដាំដំណាំ ដូចជាត្រកួននៅក្នុងបឹង និងលក់ដំណាំទាំងនេះនៅផ្សារក្នុងរាជធានីភ្នំពេញ។*
- *ផ្តល់ជូនគ្រួសារប្រជាពលរដ្ឋនូវទីកន្លែងរស់នៅមានតម្លៃសមរម្យនៅក្បែរទីក្រុង។*
- *ដើរតួនាទីយ៉ាងសំខាន់ជាអាងស្តុកធម្មជាតិសម្រាប់រំដោះទឹកជំនន់ និងរក្សាទុកកាកសំណល់រាវ។*
- *វាគឺជាបឹងធម្មជាតិដែលផ្តល់ជូនប្រជាពលរដ្ឋនូវទេសភាពដ៏ស្រស់ស្អាត។*

***បញ្ហាជាមួយនឹងគម្រោងអភិវឌ្ឍន៍:***

- *ជាច្រើនឆ្នាំកន្លងមកទឹកលិចបានកើតមានកាន់តែញឹកញាប់និងទឹកលិចនោះមានរយៈពេលកាន់តែយូរទើបស្រកអស់។*
- *លំនៅដ្ឋានត្រូវគ្របដណ្តប់ទៅដោយទឹកលិច និងកាកសំណល់ ដែលបង្កឲ្យអនាម័យ និងបរិស្ថានមិនល្អ។*
- *ជំងឺឆ្លងតាមទឹកបាននាំឲ្យមានការឆ្លងរាលដាលជំងឺ ដូចជា ជំងឺគ្រុនក្តៅ ជំងឺស្បែក និងជំងឺរាគរូស។*
- *អ្នកភូមិពុំមានប្រាក់គ្រប់គ្រាន់ក្នុងការទិញ ឬជួលទីកន្លែងផ្សេងទេ។*
- *ទឹកលិចបានបង្កការខូចខាតដោយផ្នែកទៅលើរចនាសម្ព័ន្ធលំនៅដ្ឋានមួយចំនួន។ ការរំខានដោយសំឡេង។*
- *មធ្យោបាយធ្វើដំណើរកាន់តែលំបាកដោយសារផ្លូវសំខាន់ៗត្រូវស្ទះដោយសារពុំនូកខ្សាច់។*
- *ធូលីពីខ្សាច់ និងការសាងសង់ទាំងអស់បានហុយទៅក្នុងលំនៅដ្ឋានរបស់អ្នកភូមិ ហើយប៉ះពាល់ដល់ចំណីអាហារ។*
- *វត្តមានរបស់សត្វល្អិត ពស់ និងមូសបានកើនឡើងយ៉ាងខ្លាំង។*

***សំណើសុំរបស់អ្នកភូមិ***

- *យើងខ្ញុំចង់អំពាវនាវដល់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមកជួយដល់អ្នកក្រនៅក្នុងតំបន់នេះ ពីព្រោះយើងខ្ញុំស្ថិតក្រោមគំរាមកំហែងបណ្តេញចេញ។*
- *ប្រសិនបើពួកគេផ្តល់នូវដំណោះស្រាយ ឬសំណងសមស្រប (ដី និងលំនៅដ្ឋាននៅក្នុងតំបន់ទីក្រុងដែលខ្ញុំអាចទទួលបានសេវាសាធារណៈ ដូចដែលខ្ញុំអាចនៅពេលនេះ) នោះយើងខ្ញុំនឹងពិចារណា។*
- *រាជរដ្ឋាភិបាលគួរផ្តល់សំណងដល់យើងខ្ញុំជាសាច់ប្រាក់ទៅតាមតម្លៃទីផ្សារសមស្របសម្រាប់ដីរបស់យើងខ្ញុំ។*
- *យើងខ្ញុំស្នើថារាជរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍គួរគិតគូរអំពីអ្នកក្រ និងផលប៉ះពាល់ពីគម្រោងនានាទៅលើសហគមន៍ និងបរិស្ថាន។*
- *យើងខ្ញុំអំពាវនាវដល់រាជរដ្ឋាភិបាលសូមកុំប្រើអំពើហិង្សា ឬបណ្តេញអ្នកភូមិចេញដោយបង្ខំ។*

## ឯកសារយោង:


១.Sokheng, V. (2011).Fears for more lake projects. Retrieved from http://www.phnompenhpost.com/national/fears-more-lake-projects/

២.Odom, S., & Rhoads, C. (2014).As lake disappears, a development dilemma. Retrieved fromhttps://www.cambodiadaily.com/archives/as-lake-disappears-a-development-dilemma-62718/




0 285 570 1,140 1,710
Meters

មាត្រដ្ឋាន:១:២៨,០០០
Scale: 1:28,000
ប្រព័ន្ធកូអរដោនេ:
Coordinate System:
WGS 1984 UTM Zone 48N
Projection:
Transverse Mercator
Datum: WGS 1984

អ្នកផលិតផែនទី៖ កេត ម៉េងជាង
ក្រុមអ្នកស្រាវជ្រាវ: បួ ឆៃយ៉ា, ពុំ សិលា
Author: Ket MengCheang
Survey team: Bour Chhayya, Pom Seila
កាលបរិច្ឆេទ: ០៣ មិនា ២០១៥
Date: 03-March-2015

N

ប្រភព:
គម្រោងប្លង់អភិវឌ្ឍន៍ គម្រោងប្លង់អាងស្តុកទឹមសំអុយ (អេ ហ្សិត២០១២) មរិមាណខ្សាច់ (Google earth pro, 2013, 2014, 2015), សាកលវិទ្យាល័យ វត្ត, ស្ទឹង (សធត ២០០៩) ផ្លូវសំខាន់ៗ (OpenStreetMap 2013)
Sources: AZ Proposed Development area, Proposed Sewage area (AZ, 2012), Sand Filling (Google earth pro, 2013, 2014, 2015), University, Pagoda, Stream (STT, 2009), Main Road OpenStreetMap 2013)

សមាគមធាងត្នោត
Sahmakum Teang Tnaut • a Cambodian Urban NGO

កំណត់សម្គាល់ Legend

- វត្តអារាម Pagoda
- សាកលវិទ្យាល័យ University Area
- បរិមាណខ្សាច់ឆ្នាំ ២០១៣ Sand filling 2013
- បរិមាណខ្សាច់ឆ្នាំ ២០១៤ Sand filling 2014
- បរិមាណខ្សាច់ឆ្នាំ ២០១៥ Sand filling 2015
- អូរ Stream
- គម្រោងប្លង់អភិវឌ្ឍន៍ទីក្រុងរណបបឹងទំពុន Proposed Boeung Tompun Satellite City Development Area
- គម្រោងប្លង់តំបន់ស្តុកទឹកសំអុយ Proposed Sewage Area
- គម្រោងប្លង់មហាវិថី Proposed Boulevard
- ផ្លូវសំខាន់ៗ Main Road

# បឹងទំពុនៈ អនាគតកាលមិនច្បាស់លាស់

# BOEUNG TOMPUN LAKE: FUTURE UNKNOWN?




| 0 | 1,000 | 2,000 |
|---|---|---|

Meters

មាត្រដ្ឋាន:១:៣០,០០០
**Scale:** 1:30,000
ប្រព័ន្ធកូអរដោនេ:
**Coordinate System:**
WGS 1984 UTM Zone 48N
**Projection:**
Transverse Mercator
**Datum:** WGS 1984

អ្នកផលិតផែនទី៖ ទឹម ស្រីល័ក្ខណ៍
ក្រុមអ្នកស្រាវជ្រាវ: បួ ឆៃយ៉ា, ពុំ សិលា
**Author:** Tim Sreyleak
**Survey team:**
Bour Chhayya, Pom Seila
កាលបរិច្ឆេទ: ០៣មិនា២០១៥
Data: 03-March-2015

N

ប្រភព:
ទីតាំងតំបន់ក្រីក្រក្នុងទីក្រុង(សធត ២០១៤), ព្រំប្រទល់ភ្នំពេញ (អ៊ីន អ៊ីស៊ី: ២០១៤), ព្រំប្រទល់ខណ្ឌ (អ៊ីនអ៊ីស: ២០១២), ព្រំប្រទល់សង្កាត់( អ៊ីនអ៊ីស៊ី:២០១២ ), ផ្លូវ(អូរអេសអ៊ឹម:២០១៤), ផ្លូវរថភ្លើង, ទន្លេរ និង បឹង មិនដឹងពីប្រភព

**Sourecs:**
Urban poor settlements (STT:2014), Phnom Penh boundary ( NEC: 2012), Khan boundary ( NEC: 2012), Sangkat boundary ( NEC: 2012), Road (OSM:2014), Railway, River/Lake (Unknown).

សមាគមធាងត្នោត
Sahmakum Teang Tnaut · a Cambodian Urban NGO

## កំណត់សម្គាល់ Legend

ទីតាំងលំនៅឋាន នៅតំបន់បឹងទំពុន
Settlement at Boeung Tompun Lake Area

ផ្លូវ
Road

តំបន់គម្រោងអភិវឌ្ឍន៍
Proposed Development_Area

បឹងទំពុន
Boeung Tompun Area

**Code Name**
CMN13: Deum Svay
MC55 :Prek Takong 2
MC56 :Prek Takong
MC75 :Toul Roka 4
MC78 :Prek Tanou
MC79 :Prek Takong 1
MC80 :Tnaut Chrum
MC81 :Prek Tanou 1
MC83 :Prek Talong
MC104 :Prek Tanou 2
DK38 :Chong Toul
DK46 :Cheung Aek
DK36 : Kdey Sangkheoum1/Khva

**ID Name**
1 : ISPP
2 : Next to ISPP
3 : COMIN KHMER
4 :BOREY PENG HUOTH (a)
5 :BOREY PENG HUOTH (a)
6 :Path across Development Area
7 :Under Construction 1

ទីតាំងបឹងទំពុន

